**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលឯកអគ្គរដ្ឋទូតគុយបាប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម

នៅរសៀលថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ**លោកជំទាវ** Liurka Rodriquez Barrios ឯកអគ្គរដ្ឋទូតថ្មីនៃសាធារណរដ្ឋគុយបា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម នៅទីស្តីការក្រសួង ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅ និងអបអរសាទរដល់**លោកជំទាវ** ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតថ្មីនៃសាធារណរដ្ឋគុយបា ប្រចាំរាជាណាចក្រកម្ពុជា និងបានសម្តែងការជឿជាក់ថា ចំណងមិត្តភាពដ៏យូរលង់រវាងកម្ពុជា និងគុយបា នឹងត្រូវបានពង្រីកកាន់តែស៊ីជម្រៅថែមទៀត ក្នុងអាណត្តិការងាររបស់លោកជំទាវ ចំពេលខួប៦០ឆ្នាំនៃទំនាក់ទំនងការទូតប្រទេសទាំងពីរ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ពីការត្រៀមផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធនិងពេញលេញរបស់កម្ពុជា ដល់ការបំពេញបេសកកម្មការទូតរបស់លោកជំទាវនៅកម្ពុជា។

ជាការឆ្លើយតប **លោកជំទាវ** Liurka Rodriquez Barrios បានសម្តែងនូវសេចក្តីរីករាយដោយបានទទួលការតែងតាំងជាឯកអគ្គរដ្ឋទូតប្រចាំនៅកម្ពុជា និងបានកោតសរសើរចំពោះការរីកចម្រើនយ៉ាងឆាប់រហ័សលើគ្រប់វិស័យរបស់កម្ពុជា។ ក្នុងនាមរដ្ឋាភិបាល និងប្រជាជនគុយបា **លោកជំទាវឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណដល់រដ្ឋាភិបាលកម្ពុជា ដែលជានិច្ចកាល តែងតែគាំទ្រដល់បុព្វហេតុត្រឹមត្រូវរបស់រដ្ឋាភិបាលនិងប្រជាជនគុយបា ក្នុងការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពជាតិ និងទាមទារឱ្យបញ្ឈប់ជាបន្ទាន់ការដាក់ទណ្ឌកម្មជាឯកតោភាគីដ៏អយុត្តិធម៌ប្រឆាំងគុយបា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង**លោកជំទាវឯកអគ្គរដ្ឋទូត** បានពិភាក្សាពីលទ្ធភាពនៃការបំពេញទស្សនកិច្ចផ្លូវការរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅប្រទេសគុយបា ដែលនឹងអាចប្រព្រឹត្តទៅនៅក្នុងខែមីនាខាងមុខ ដើម្បីអបអរសាទរខួប៦០ឆ្នាំនៃទំនាក់ទំនងការទូតរវាងកម្ពុជានិងគុយបា។

ពាក់ព័ន្ធនឹងទំនាក់ទំនងទ្វេភាគី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង**លោកជំទាវឯកអគ្គរដ្ឋទូត** បានសំដែងការពេញចិត្តចំពោះលទ្ធផលនៃកិច្ចពិគ្រោះយោបល់នយោបាយលើកទី១រវាងមន្ត្រីជាន់ខ្ពស់ក្រសួងការបរទេសទាំងពីរ កាលពីឆ្នាំមុន។ ភាគីទាំងពីរ មានសុទិដ្ឋិនិយមថា យន្តការពិគ្រោះយោបល់

ទ្វេភាគីនេះ នឹងជួយធ្វើឱ្យទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរ កាន់តែជិតស្និទ្ធ និងទូលំទូលាយថែមទៀត ជាពិសេសលើវិស័យអប់រំ ពាណិជ្ជកម្ម ទេសចរណ៍ និងសុខាភិបាល។ នៅចន្លោះឆ្នាំ១៩៨៣ ដល់ឆ្នាំ២០១៧ រដ្ឋាភិបាលគុយបា បានផ្តល់អាហារូបករណ៍ ដល់សិស្ស-និស្សិតកម្ពុជាចំនួនប្រមាណ១៦២រូប ហើយបច្ចុប្បន្ន មាននិស្សិតកម្ពុជាចំនួន១៧រូប កំពុងសិក្សានៅទីនោះ។

ក្រៅពីនេះ ភាគីទាំងពីរ ក៏បានផ្លាស់ប្តូរទស្សនៈគ្នាអំពីបញ្ហាតំបន់ និងអន្តរជាតិ ដែលជាកង្វល់ និងមានប្រយោជន៍រួម៕

--------------------------